**និយ័តករបរធនបាលកិច្ច**

**TRUST REGULATOR**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង ន.ប.ធ. ស្តីពី "គោលការណ៍ណែនាំ និង នីតិវិធីផ្ទៃក្នុង ស្តីពីការរៀបចំនិងការអនុវត្តថវិកាកម្មវិធីរបស់ ន.ប.ធ." ក្នុងក្របខណ្ឌនៃការអនុវត្ត សកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ថ្ងៃព្រហស្បតិ៍ ១០រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ភ្នំពេញ, ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២

នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នៅព្រឹកថ្ងៃព្រហស្បតិ៍ ១០រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី "**គោលការណ៍ណែនាំ និងនីតិវិធីផ្ទៃក្នុង ស្តីពីការរៀបចំនិងការអនុវត្តថវិកាកម្មវិធីរបស់ ន.ប.ធ.**" ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាននៃ **ន.ប.ធ.** នៅទីស្តីការ **អ.ស.ហ.**។

សិក្ខាសាលានេះ បានរៀបចំឡើងក្នុងគោលបំណងដើម្បីជាមគ្គុទេសក៍សម្រាប់ជួយណែនាំអំពីវិធីសាស្ត្រនៃការរៀបចំ និងអនុវត្តថវិកាដល់គ្រប់នាយកដ្ឋាននៃ **ន.ប.ធ.** ដែលអនុវត្តផែនការសកម្មភាពនៃកញ្ចប់ថវិការបស់ **ន.ប.ធ.**។ គោលការណ៍ណែនាំនេះ ក៏ជាកម្មវត្ថុដែលអាចធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ដើម្បីកែលម្អជាប្រចាំ និងធានាឱ្យការអនុវត្តកម្មវិធីមានគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ទៅតាមបទពិសោធន៍នៃការអនុវត្តជាក់ស្តែង និងបទពិសោធន៍ដែលទទួលបានពីវគ្គបណ្តុះបណ្តាល និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។